# សេវាកម្មផ្អែកលើសាលា RI Medicaid

## តើមានន័យយ៉ាងដូចម្ដេចចំពោះអ្នក និងកូនរបស់អ្នក



### ការរំលឹកលើកដំបូង និងប្រចាំឆ្នាំ

ប័ណ្ណផ្សព្វផ្សាយដែលបង្កើតឡើងដោយគម្រោងជំនួយបច្ចេកទេស (RITAP) នៅ Rhode Island សម្រាប់ក្រសួងអប់រំ (RIDE) នៅ Rhode Island ដោយសហការជាមួយបណ្ដាញមាតាបិតាសិស្ស (RIPIN) នៅ Rhode Island ។

## ការព្រមព្រៀងពីមាតាបិតាក្នុងការទទួលយកគម្រោង Medicaid

ច្បាប់ទូទៅ 40-8-18 នៅ Rhode Island អនុញ្ញាតឱ្យស្ថាប័នអប់រំមូលដ្ឋាន (LEAs- សំដៅលើមណ្ឌលសាលា ឬសាលារដ្ឋ) នៅ Rhode Island ដើម្បីទទួលបានការទូទាត់សំណង សម្រាប់ការវាយតម្លៃមួយចំនួន និងសេវាទាក់ទងនឹងការអប់រំពិសេស ដែលផ្ដល់ជូនកុមារដែលមានសិទ្ធិទទួលបានគម្រោង Medicaid។ ច្បាប់ស្ដីពីការអប់រំសម្រាប់ជនពិការ (IDEA) តម្រូវឲ្យស្ថាប័ន LEAs ជូនដំណឹងដល់មាតាបិតាសិស្សមុននឹងទទួលបានការយល់ព្រមជាមុនសិន ហើយនិងជូនដំណឹងដល់មាតាបិតាសិស្សអំពីសកម្មភាពនេះជារៀងរាល់ឆ្នាំ។

LEAs ត្រូវតែទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរ**ម្ដង**ពីមាតាបិតាសិស្សមុននឹងទទួលបានការទូទាត់សំណងពីគម្រោង Medicaid ។ ជារៀងរាល់ឆ្នាំ ស្ថាប័ន LEAs ត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកអំពីលក្ខខណ្ឌនេះ ។ ការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នកអាចដកហូតវិញបាន (ដក) នៅពេលណាមួយក៏បានបន្ទាប់ពីបានប្រគល់ជូន។ ប្រសិនបើអ្នកដកហូតការយល់ព្រម ការដកហូតនោះគឺមិនមានប្រសិទ្ធភាពទេ (វាមិនអនុវត្តចំពោះសំណងដែលស្ថាប័ន LEA ស្វែងរកបន្ទាប់ពីអ្នកបានផ្ដល់ការយល់ព្រម ហើយមុនថ្ងៃដែលមណ្ឌលបានទទួលការដក /ការដកហូតរបស់អ្នកដើម្បីផ្ដល់ការយល់ព្រម។ )

មូលនិធិគម្រោង Medicaid ដែលស្ថាប័ន LEA របស់អ្នកទទួលបាន ត្រូវបានប្រើប្រាស់ដើម្បីគាំទ្រដល់ការអប់រំសម្រាប់រាល់សិស្សទាំងអស់នៅក្នុងមណ្ឌលរបស់អ្នក។ ជាមួយការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នក អាចទទួលបានការទូទាត់សំណងពីគម្រោង Medicaid សហព័ន្ធសម្រាប់សេវាដែលឧបត្ថម្ភគាំទ្រដោយមូលនិធិអប់រំក្នុងមូលដ្ឋាន និងរដ្ឋ។ ការទទួលបានមូលនិធិទាំងនេះមិនបានប៉ះពាល់ដល់សិទ្ធិរបស់កូនអ្នកក្នុងការទទួលបានការអប់រំសាធារណៈដោយឥតគិតថ្លៃ និងសមស្រប (FAPE) នៅក្នុងបរិយាកាសរឹតបន្តឹងតិចតួចបំផុត (LRE)។

នេះមានន័យថានឹង**មិនមានការចំណាយសម្រាប់គ្រួសាររបស់អ្នក** ដែលរួមបញ្ចូលទាំងការមិនមានការបង់រួមគ្នា គ្មានប្រាក់កាត់កង ការមិនបាត់បង់សិទ្ធិទទួលបានគម្រោង Medicaid ឬផលប៉ះពាល់ណាមួយទៅលើអត្ថប្រយោជន៍ពេញមួយជីវិតពីគម្រោង Medicaid។ **ករណីលើកលែង**តែមួយគត់ចំពោះការមិនចំណាយអាចជាឧបករណ៍បច្ចេកវិទ្យាជំនួយ (AT) ។ ក្រុមគ្រួសារ និងមណ្ឌលត្រូវតែប្រើប្រាស់**ទម្រង់បែបបទយល់ព្រមដាច់ដោយឡែកសម្រាប់ឧបករណ៍ AT** ដោយសារតែស្ថាប័ន Medicaid របស់រដ្ឋ អាចបដិសេធមិនឲ្យក្រុមគ្រួសារទិញឧបករណ៍សម្រាប់ប្រើប្រាស់នៅក្នុងផ្ទះប្រសិនបើសាលាបានស្វែងរកសំណងសម្រាប់ឧបករណ៍ដូចគ្នា។

## សេវារួមទាំងការវាយតម្លៃមួយចំនួនដែលអាចទូទាត់សងដោយគម្រោង Medicaid៖

- ការព្យាបាលដោយចលនា
- ការព្យាបាលដោយឲ្យអ្នកជំងឺធ្វើសកម្មភាពផ្សេងៗ
- ការព្យាបាលការនិយាយស្ដាប់ និងភាសា
- ការពិនិត្យការផ្សព្វផ្សាយដល់កុមារ
- ការគ្រប់គ្រងករណី
- ការប្រឹក្សា
- ការដឹកជញ្ជូន
- ការថែទាំជំងឺ
- ការថែទាំផ្ទាល់ខ្លួន
- ការព្យាបាលតាមកម្មវិធីពេលថ្ងៃ
- ការព្យាបាលតាមកម្មវិធីលំនៅដ្ឋាន
- សេវាបច្ចេកវិទ្យាជំនួយ (មិនរួមបញ្ចូលឧបករណ៍មួយចំនួន)



គាំទ្រដល់សាលារបស់យើង!

## ចំពោះព័ត៌មានបន្ថែម៖

www.ride.ri.gov/StudentsFamilies/Overview.aspx

www.ritap.org/medicaid

www.ripin.org

www.psnri.org

www.eohhs.ri.gov/ProvidersPartners/GeneralInformation/ProviderDirectories/LocalEducationAgency.aspx

www2.ed.gov/policy/speced/reg/idea/part-b/part-b-parental-consent.html

សម្រាប់ជំនួយអំពីការខ្វែងគំនិតគ្នាជាមួយនឹងសាលារបស់អ្នកអំពីបញ្ហាអប់រំពិសេស សូមទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលអប់រំពិសេសតាមរយៈលេខ៖ 401–222–8999៖